ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាជំនុំ រដ្ឋប្បវេណី

សំណុំរឿង រដ្ឋប្បវេណី

លេខ : ៣៨៦

ចុះថ្ងៃទី២៤ខែធ្នូឆ្នាំ ១៩៩៨

សាលដីកា

លេខ : ៥៣

ចុះថ្ងៃទី១៤ខែមិថុនាឆ្នាំ២០០០

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្ទី ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២ - លោក ខឹប៉ន ស៊ុន ជាចៅក្រម

៣ - លោក ទៀល មួន ជាចៅក្រមរបាយការណ៍

៤ - លោក ប្រាក់ គីមសាន ជាចៅក្រម

៥ - លោក សោម សិរីវឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី ឡូង ចន្ថាធី

តំណាង មហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើសាលដីការដ្ឋប្បវេណីលេខ ៦៤៦ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ លោក ប្រឹង ផាន់ជី អាយុ ៥០ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ប្រធានក្រុមហ៊ុនសុរាធារាខ្មែរ ទីលំនៅផ្ទះលេខ ១៧៤០ អ៊ីសូឌៀ ក្រុម ១៣ - សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិអោយទៅលោក យួន ហួត ។

និងចុងបណ្តឹងសាទុក្ខឈ្មោះលោក ស៊ូ ផាត អាយុ ៤៧ ឆ្នាំ ជាតិ ខ្មែរ មុខរបរ គ្រូពេទ្យ ទីលំនៅផ្ទះលេខ ៥៨ អ៊ីសូឌៀ ផ្លូវលេខ ៣១០ ក្រុមទី ១៣ សង្កាត់បឹងកេងកង១ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ ។

កម្មវត្ថុបណ្តឹង : ប្តឹងបញ្ជាប់មិនអោយធ្វើការ

បានឃើញបណ្តឹងសាទុក្ខលេខ ៤០៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ លោក ប្រឹង ផាន់ជី ប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ទាំងស្រុង ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ របស់ដើមចោទឈ្មោះលោក ខូវ ចន្ថា ជាមេធាវីតំណាងអោយលោក ស៊ូ ផាត ប្ដឹងសុំទាមទារប្រាក់បំណាច់តាមច្បាប់ការងារ និង ទារជម្ងឺចិត្តជាប្រាក់ចំនួន ១២០០ដុល្លាអាមេរិច ពីក្រុមហ៊ុនសុរាគារខ្មែរ ដោយមូលហេតុ ក្រុមហ៊ុននេះបានបញ្ឈប់ការងារកូនក្ដីខ្លួនដោយគ្មានមូលហេតុសមស្រប ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១១៨ " ត " ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៨៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ២២.១១.១៩៨៦ របស់លោក ខូវ ចន្ថា ជាមេធាវីនៃអង្គការតំរោងអ្នកការពារក្ដីកម្ពុជា តំណាងលោក ស៊ូ ផាត ជាដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង - គតិច្បាប់ ។

២ - បង្គាប់អោយក្រុមហ៊ុនសុរាគារខ្មែរដែលមានលោក ប្រឹង ផាននី ជាតំណាងផ្ដល់ប្រាក់បំណាច់បណ្ដេញចេញចំនួន ២៥០ ដុល្លាអាមេរិច និង ប្រាក់ជម្ងឺចិត្តចំនួន ១០០ ដុល្លាអាមេរិច អោយទៅលោក ស៊ូ ផាត តាមមាត្រាទី ៨៥ និង ១០៧ នៃច្បាប់ការងារ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៩៩ ក្រ ចុះថ្ងៃទី ១៣.១០.១៩៧២ ។

- សំណូមពរជម្ងឺចិត្តលើសពីនេះត្រូវបដិសេធចោល ។

៣ - បង្គាប់អោយលោក ស៊ូ ផាត បង់ប្រាក់ប្រដាប់ក្ដីគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹងចំនួន - ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីការពិចប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច។

- កាលបើផុតបណ្ដឹងឧទ្ធរណ៍ហើយ បង្គាប់អោយលោក ប្រឹង ផាននី យកប្រាក់ ៧.០០០រៀល ទៅអោយដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រមួយភាគរយលើទឹកប្រាក់ចំនួន ៣៥០ដុល្លារមេរិច - ប្រាក់នេះត្រូវបង់ចូលថវិការរដ្ឋ ៨០ ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយ តាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ។

៤ - សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្ដី សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ ចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៦០ " គ " ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៨៧ របស់ឈ្មោះ លោក ប្រឹង ផាននី ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចនៃសាលក្រមរបស់តុលាការក្រុងភ្នំពេញទាំងស្រុង ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៥៦ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៨៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១ - ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៩.១២.១៩៨៧ របស់ឈ្មោះ ប្រឹង ផាននី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលក្រមលេខ ១១៨ "ត" ១៧.១២.១៩៨៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣ - ទីបរូបប្រាក់ប្រចាំខែដែលដើមបណ្តឹងទទួលបានបង់រួចហើយគឺ ពន្ធចុះបញ្ជី និង ពន្ធផ្លូវ ២.៥៥០ រៀល រង្វាន់ក្រឡាបញ្ជីកាត់ពីប្រាក់ ៤៥០ រៀល ចំណាយលើការប្រគល់ដីការកោះ ៥០០០ រុ០០ និង អាជ្ញាធរតុលាការ ៥.០០០ រៀល ។

៤ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពារ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់ឈ្មោះ ប្រឹង ផាន់នី ជាម្ចាស់បណ្តឹងសាទុក្ខ ។

បានឃើញសារណាតបចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ស៊ូរ ផាត ជាចុងបណ្តឹងសាទុក្ខ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ថា:

សាលដីការដ្ឋប្បវេណីលេខ ៦៤៦ ចុះថ្ងៃទី ១២.១០.១៩៩៨ របស់សាលាឧទ្ធរណ៍បានសំរេចត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និង ពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឃួន ទួត " ទទួលសិទ្ធិពីឈ្មោះ ប្រឹង ផាន់នី " ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា បានដាក់ខ្លួនប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ពីព្រោះខ្លួនពុំព្រមបង់ប្រាក់ជូនលោក ស៊ូរ ផាត តាមដែលសាលាឧទ្ធរណ៍បង្គាប់នោះទេ ដោយលោក ស៊ូរ ផាត បានធ្វើការក្នុងក្រុមហ៊ុនយើងខ្ញុំបានតែ ៥ឆ្នាំ ៣ខែ ២៧ថ្ងៃ គិតចាប់តាំងពីការងាររបស់ក្រុមហ៊ុនយើងខ្ញុំដំណើរការតពីរដ្ឋ ដូចនេះបើសិនយើងខ្ញុំត្រូវបង់ជូនគឺខ្លួនបង់តែ ៦ ខែ ដែនប្រាក់បៀវត្សរ៍របស់គាត់មីខ្លួនស្មើនឹង ១៨០ដុល្លា ទេ អាស្រ័យដូចហេតុដែលរាបជូនខាងលើ សូមលោកប្រធានតុលាការមេត្តារកយុត្តិធម៌អោយយើងខ្ញុំដោយអនុ-គ្រោះផង ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ស៊ូរ ផាត ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា បន្ទាប់ពីបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យវិទ្យាសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ ក្រសួងសុខាភិបាលបានចាត់តាំងខ្លួនអោយផ្លាស់ពីឱសថស្ថានក្រសួងសុខាភិបាលទៅធ្វើការនៅរោងចក្រសុរា-ការកម្ពុជានៅថ្ងៃទី ២២.៦.១៩៨៦ ដូចនេះទៀងនេះខ្លួនសុំអាងលើលិខិតចាត់តាំង និង សញ្ញាប័ត្រជាសក្ខីភាព និង សូមអោយតុលាការកំពូលមេត្តាផ្តល់យុត្តិធម៌ដល់ខ្ញុំបាទដោយអនុគ្រោះ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤០៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកាឆ្នាំ១៩៩៨របស់លោកប្រឹង ផានី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកឡើងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីការចាត់តាំង និង សកម្មភាពរបស់តុលាការជំរះក្តី ។

- យល់ឃើញថា ថ្វីបើកាលបរិច្ឆេទចូលបំពេញការងាររបស់លោក សូរ ផាត ពុំមានការឯកភាពគ្នាក៏ពិតមែន ប៉ុន្តែតាមប្រកាស ២០ នៃកិច្ចសន្យាចុះថ្ងៃទី ៣១.១០.៩០ និង មាត្រា ២៩៣ នៃច្បាប់ការងារ លោក សូរ ផាត ត្រូវបានទទួលអត្ថប្រយោជន៍តាមកិច្ចសន្យាខាងលើ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦៤៦ ចុះថ្ងៃទី ១២.១០.១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១ - ទទួលបណ្តឹងសាទុក្ខលេខ ៤០៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់លោកប្រឹង ផានី តំណាងអោយក្រុមហ៊ុនសុរាគារខ្មែរទុកជាត្រឹមត្រូវតាមទម្រង់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីការដ្ឋប្បវេណីលេខ ៦៤៦ ចុះថ្ងៃទី ១២.១០.១៩៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣ - វិភាគប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក ប្រឹង ផានី បានបង់ដូចតទៅនេះ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធតាំង ចំនួន ៤.០០០ រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ផ្សារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយក្នុងការប្រគល់ដីការកោះចំនួន ១៥.០០០ រៀល សរុប ១៩.០០០ រៀល ។ ហើយត្រូវអោយក្រុមហ៊ុនសុរាគារខ្មែរបង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០០ ។